**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
**តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

COHCHR

# ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ ២០០២

ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០២ - ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០០២

អ្វីដែលអាចកើតមានឡើង នៅក្នុងរយៈពេលយុទ្ធនាការនៃការឃោសនាបោះឆ្នោត និងក្រោយការបោះឆ្នោត

នៅក្នុងរបាយការណ៍របស់លោក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០២ លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានពិនិត្យបញ្ហាដែលបានកើតមានឡើងក្នុងរយៈពេលមុនយុទ្ធនាការនៃការបោះឆ្នោត ។ មេរៀនដែលនឹងទាញបានពីរយៈពេលនៃការឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោតតែម្តង នឹងត្រូវវែកញែកដោយស៊ីជំរៅថែមទៀតនៅក្នុងរបាយការណ៍មួយជាបន្ទាប់ទៀត ដែលនឹងត្រូវចេញផ្សាយនៅក្នុងខែមីនា ។ សេចក្តីថ្លែងការណ៍នាយៈពេលចន្លោះនេះ មានទិសដៅដើម្បីបញ្ចៀសបញ្ហាដែលកើតឡើងភ្លាមក្រោយការបោះឆ្នោត និងផ្តល់ជូនអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងទិសដៅនេះឯង ។

## រយៈពេលនៃយុទ្ធនាការនៃការបោះឆ្នោត

អំពើហិង្សា និងភាពមិនទៀងទាត់នៃការបោះឆ្នោត បានបន្តកត់សំគាល់ឃើញនៅក្នុងពេលឆ្ពោះទៅការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ថ្ងៃទី ៣ កុម្ភៈ ។ ទោះបីជាមានបរិយាកាសស្ងប់ស្ងាត់ដោយប្រៀបធៀប បានកើតមានឡើងនៅថ្ងៃដំបូង ៗ ក៏ដោយ ក៏ក្មេងអាយុ ២ ឆ្នាំ ម្នាក់ បានត្រូវសម្លាប់នៅថ្ងៃទី ២៥ ខែមករា នៅពេលមនុស្សកាន់កាំភ្លើងបំរុងបាញ់ទៅលើឪពុកក្មេងនេះ ដែលជាបេក្ខជនម្នាក់នៅក្នុងខេត្តបន្ទាយមានជ័យមកពីគណបក្សប្រជាជនកម្ពុជា ។ ការស្លាប់ថ្មី ៗ មួយចំនួន ត្រូវបានជូនដំណឹងដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នៅក្នុងរយៈពេលនេះ តែពុំមានអ្វីបញ្ជាក់ថាការស្លាប់ទាំងនេះមានអ្វីទាក់ទិននឹងការបោះឆ្នោតនោះទេ ។ ជាទូទៅមានការកើនឡើងនៃបញ្ហាបំភិតបំភ័យ នៅក្នុងអាទិត្យទី ២ នៃយុទ្ធនាការ ។

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

ដើម្បីធានាថាសិទ្ធិមនុស្ស ត្រូវបានការពារ និងប្រព្រឹត្តតាម នៅក្រោយពេលបោះឆ្នោត ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះខេត្តកំពង់ចាម ។ ទោះបីជាសភាពការណ៍ប្រែប្រួលពីស្រុកមួយទៅស្រុកមួយក៏ដោយ ក៏ខេត្តនេះទទួលរងការឈឺចាប់ ដោយឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ជាងគេ ទាក់ទងនឹងការបោះឆ្នោត ជាងខេត្តណាដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។ ការខិតខំរបស់អាជ្ញាធរ ដើម្បីទប់ស្កាត់ក្រុមជនពាលប្រដាប់អាវុធកុំឱ្យធ្វើសកម្មភាពនៅស្រុកត្បូងឃ្មុំ បាននាំទៅឱ្យមានការចាប់ខ្លួនមួយចំនួន នៅក្នុងពេលថ្មី ៗ កន្លងទៅនេះ ។ ទាំងនេះជាការវិវត្តន៍គួរឱ្យស្វាគមន៍ ។ ប៉ុន្តែ វិធានការចីរភាពទៅលើនិទ្ទណ្ឌភាព និងអំពើហិង្សា ក៏ទាមទារឱ្យធ្វើឡើងដែរដើម្បីឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ថ្មី អាចដំណើរការទៅបាន ។ ការស្លាប់ចំនួន ៥ នាក់ បានកើតមានឡើងនៅក្នុងខេត្តនេះ នៅក្នុងរយៈពេលមុនយុទ្ធនាការ និងនៅក្នុងពេលយុទ្ធនាការបោះឆ្នោត ។ បេក្ខជនគណបក្សហ៊្វុនស៊ិនប៉ិចនៃឃុំស្រឡប់ មិនហ៊ានដេកនៅក្នុងផ្ទះរបស់ខ្លួន ឬធ្វើសកម្មភាពសំរាប់ការបោះឆ្នោតសេរី ដោយពុំមានការភ័យខ្លាចទេ ។ ក្រុមជនពាលដែលបានសន្មត់ថាជាអ្នកសម្លាប់សកម្មជនគណបក្សសមរង្ស៊ី និងហ៊្វុនស៊ិនប៉ិច កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅក្នុងឃុំស្រឡប់ បានបន្តធ្វើឱ្យមានការភ័យខ្លាចដល់សហគមន៍នៅទីនោះ។ ខ្សែខ័ណ្ឌរវាងឧក្រិដ្ឋកម្មនយោបាយ និងមិននយោបាយ បានធ្វើឱ្យស្រពិចស្រពិលរហូតដល់ចំណុចមួយដែលឧប្បត្តិហេតុកើតឡើងដោយមូលហេតុដែលស្មានមិនដល់ - រួមមានការស្លាប់ដោយគ្រោះថ្នាក់ - បណ្តាលឱ្យមានការភ័យខ្លាចក្នុងចំណោមអ្នកបោះឆ្នោតជាទូទៅ ។ ឧក្រិដ្ឋកម្មនេះ និងនយោបាយ បានប្រតឹងប្រគងលើគ្នា រហូតដល់ក្លាយទៅជាបញ្ហាមួយនៃការព្រួយបារម្ភយ៉ាងខ្លាំង ។ អំពើហិង្សា និងការបំភិតបំភ័យ មិនត្រូវធ្វើឱ្យរអាក់រអួលដល់កិច្ចដំណើរការ នៃក្រុមប្រឹក្សាឃុំ/សង្កាត់ នាពេលខាងមុខនេះទេ ។

សេចក្តីថ្លែងការណ៍នានា នាពាក់កណ្តាលខែមករាកន្លងទៅនេះ របស់សម្តេចនាយករដ្ឋមន្ត្រី អំពាវនាវឱ្យមានការស្ងប់ស្ងាត់ក្នុងការបោះឆ្នោត ព្រមទាំងសេចក្តីផ្តើមគំនិតរបស់គណៈរដ្ឋមន្ត្រីនាពេលថ្មី ៗនេះ ហាក់ដូចជានាំឱ្យមានបច្ច័យល្អ ។ ការពុំកើតមានអំពើហិង្សាដ៏ធ្ងន់ធ្ងរ ក្នុងថ្ងៃដំបូង ៗ នៃយុទ្ធនាការ អាចទាក់ទិនទៅនឹងការណ៍នេះ ។ ការចាប់ខ្លួននាពេលថ្មី ៗ កន្លងទៅនេះ បានកើតមានឡើងយ៉ាងតិចនៅក្នុងខេត្តចំនួន ២ ទោះបីជាការនេះមិនសុទ្ធតែបានធ្វើឡើងស្របទៅតាមបែបបទដែលមានចែងនៅក្នុងច្បាប់ក៏ដោយ ។ ត្រង់នេះ លោកតំណាងពិសេសសូមផ្តល់អនុសាសន៍មួយចំនួនដូចតទៅ ។ ទី ១ គឺវាជាការសំខាន់ណាស់ ដែលបែបបទតុលាការ និងព្រហ្មទ័ណ្ឌ ត្រូវធ្វើឡើងឱ្យស្របទាំងស្រុងទៅនឹងច្បាប់ ដែលចែងឡើងដើម្បីការពារអ្នកស្លូតត្រង់ ក៏ដូចជាដើម្បីផ្តន្ទាទោសជនល្មើស ។ ដូចដែលសម្តេចនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ជាច្រើនលើកច្រើនសាមកហើយ នីតិរដ្ឋមិនត្រូវបន្ទុចបង្អាក់ដោយឥទ្ធិពលនៃខ្សែរយៈ ឬឋានន្តរសក្តិឡើយ ។ ទី ២ អាជ្ញាធរមានពាក់ព័ន្ធត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ និងដោយហ្មត់ចត់ នូវការចោទប្រកាន់ទាំងអស់ស្តីពីអំពើហិង្សា និងការបំភិតបំភ័យ និងនាំខ្លួនពួកអ្នកទទួលខុសត្រូវឱ្យទទួលផលនៃអំពើរបស់ខ្លួន ។ ទី ៣ ការចាប់ខ្លួនទាំងអស់ត្រូវធ្វើស្របទៅតាមច្បាប់ជាធរមាន និងដោយឈរលើភស្តុតាងចោទប្រកាន់ជាដុំកំភួន ។ ទី ៤ ការកាត់ទោសទាំងអស់ ត្រូវធ្វើឡើងស្របទៅតាមបទដ្ឋាននៃការកាត់ក្តីត្រឹមត្រូវ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។

ការសន្មត់ជាមុនថាគ្មានទោស ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ត្រូវតែគោរពចំពោះគ្រប់ករណីទាំងអស់ ។ ចំណុចសំខាន់មួយនៅទីនេះគឺ បេក្ខជនឃុំ/សង្កាត់ និងសកម្មជននយោបាយ ត្រូវអនុញ្ញាតឱ្យប្រើប្រាស់សិទ្ធិនយោបាយជាបឋមរបស់ពួកគេ និងត្រូវទទួលបាននូវកិច្ចការពារដោយពេញលេញ ដោយពុំគិតពីខ្សែនយោបាយរបស់ពួកគេឡើយ ។

## ការស្លាប់ដោយគ្រោះថ្នាក់

រហូតមកទល់ពេលនេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា រកមិនទាន់ឃើញភស្តុតាងដែលភ្ជាប់ការស្លាប់ ដែលបានកើតឡើងនៅក្នុងរយៈពេលនៃយុទ្ធនាការ ដោយគ្រោះថ្នាក់ចរាចរ ទៅនឹងឧក្រិដ្ឋកម្មនយោបាយទេ ។ ក៏ប៉ុន្តែ និងដូចដែលបានជូនយោបល់នៅក្នុងរបាយការណ៍ចុះថ្ងៃទី ១១ ខែមករា របស់ខ្ញុំ អាជ្ញាធរត្រូវតែធ្វើការស៊ើបអង្កេតដោយហ្មត់ចត់ និងដោយពុំមិនធ្វើការវាយតម្លៃជាមុន ហើយត្រូវធ្វើឱ្យឃើញថាបានធ្វើយ៉ាងដូច្នេះមែន។ កិច្ចសហប្រតិបត្តិការល្អជាងនេះ ពីគណបក្សមួយទៅគណបក្សមួយ ចំពោះបញ្ហាបែបនេះ នឹងជួយដល់កិច្ចដំណើរការនេះ ។ ទូទៅជាងនេះទៅទៀត ត្រូវកត់សំគាល់ថា នៅពេលដែលមន្ត្រីរដ្ឋាភិបាលប្រកាសថាការស្លាប់ណាមួយមិនមែនជារឿងនយោបាយ មុនត្រូវបានស៊ើបអង្កេតដោយពេញលេញនោះ អំពើនេះនឹងបង្កើតនូវការលំអៀងមួយ ដែលធ្វើឱ្យរឿងនេះក្លាយទៅជារឿងនយោបាយមួយភ្លាម ។ ការដោះស្រាយបញ្ហានិទ្ទណ្ឌភាព ទាមទារផ្តល់ឱ្យអាជ្ញាធរស៊ើបអង្កេតដើរដល់ការសន្និដ្ឋានមួយចាកផុតពីការជ្រៀតជ្រែកបែបនេះ ។

## ការជៀសវាងបញ្ហាក្រោយការបោះឆ្នោត

នៅពេលបោះឆ្នោតជាតិឆ្នាំ ១៩៩៨ ការភ័យខ្លាចការសងសឹក បានធ្វើឱ្យបេក្ខជនមួយចំនួនធំដែលចាញ់ឆ្នោតរត់ចោលភូមិរបស់ពួកគេ និងស្វែងរកការការពារខ្លួន នៅក្នុងការិយាល័យរបស់គណបក្ស នៅតាមខេត្ត និងនៅភ្នំពេញ ។ ក្រុមប្រជាពលរដ្ឋដែលត្រូវបានគេជិះជាន់នេះ បានផ្តល់ជាឥន្ទនៈសំរាប់ការតវ៉ានៅក្រោយពេលបោះឆ្នោត ។ ដោយមានប្រវត្តិបែបនេះ និងវិធីហិង្សាដែលការតវ៉ានេះបានបញ្ចប់ លោកតំណាងពិសេសមានសេចក្តីព្រួយបារម្ភជាខ្លាំងស្តីពីសក្តានុពលនៃអំពើហិង្សានៅកន្លែងខ្លះ នៅក្រោយពេលបោះឆ្នោត ។ រដ្ឋាភិបាលត្រូវបានអំពាវនាវឱ្យធ្វើសេចក្តីថ្លែងការណ៍ជាបន្ទាន់ និងដោយមិនពាំត្រលោតមួយថា ការសងសឹកប្រឆាំងទៅលើអ្នកចាញ់ ឬអ្នកឈ្នះ នឹងមិនត្រូវអត់ឱនឱ្យទេ ។ គណបក្សនយោបាយទាំងអស់ ត្រូវប្រើការអត់ធ្មត់ ដើម្បីឱ្យលទ្ធផលនៃការបោះឆ្នោត ត្រូវបានទទួលយកដោយពុំមានទំនាស់ ។ វាជាការស្លាប់រស់ផងដែរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលទទួលបន្ទុកខាងការដោះស្រាយពាក្យបណ្តឹង ត្រូវធ្វើឱ្យឃើញថាខ្លួនបានដោះស្រាយបញ្ហាទាំងនេះដោយតម្លាភាព និងដោយត្រឹមត្រូវ ។ គ្មានការជ្រៀតជ្រែកដោយហួសហេតុណាមួយ ត្រូវបានអនុញ្ញាតឱ្យប្រើឥទ្ធិពលលើកិច្ចដំណើរការនេះទេ ។